00221485

C22/I/68

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

ចំពោះមុខ: ចៅក្រម ប្រាក់ គីមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២៨ សីហា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28/08/2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

សាធារណៈ:

**សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង**

ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 28/08/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

**ការិយាល័យសហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT
យ៉ែត ចរិយា
William SMITH
តាន់ សេណារ៉ុង
Anees AHMED

**ជនត្រូវចោទ**
អៀង សារី

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke Studzinsky
យុង ផានិត

**សហមេធាវីការពារក្តី**
អាង ឧត្តម
Michael G. KARNAVAS

PRE-TRIAL CHAMBER · CHAMBRE PRELIMINAIRE · ECCC

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" ទទួលបាន "ពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដែលដើមបណ្តឹងរដ្ឋប្បវេណី **សេខ ចំនួនធារី** បានដាក់នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨ ("ពាក្យសុំពិចារណាសារជាថ្មី")។

២. ពាក្យសុំពិចារណាសារជាថ្មី ជាភាសាអង់គ្លេស ត្រូវបានដើមបណ្តឹងរដ្ឋប្បវេណី **សេខ ចំនួនធារី** ដាក់ជូនអង្គបុរេជំនុំជម្រះ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ ក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ដែលសវនាការនេះបានបញ្ចប់នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨។ ដើមបណ្តឹងរដ្ឋប្បវេណីបានចាកចេញពីបន្ទប់សវនាការ ដោយធ្វើការរង់ចាំការដាក់ពាក្យសុំពិចារណាសារជាថ្មីរបស់ខ្លួន និងដោយរង់ចាំការចេញដីកាសម្រេចលើពាក្យសុំនេះ។ ពាក្យសុំពិចារណាសារជាថ្មី ត្រូវបានដាក់ត្រឹមត្រូវ អនុលោមតាមសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក នៅពេលពាក្យសុំជាភាសាខ្មែរបានរៀបចំរួចរាល់នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០០៨។

៣. នៅក្នុងសេចក្តីបង្គាប់របស់ខ្លួនស្តីពី "សេចក្តីបង្គាប់លើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ" ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានលើកឡើងថា នៅក្នុងដំណាក់ការនេះ ពាក្យសុំពិចារណាសារជាថ្មីគួរចាត់ទុកថាជា សំណើសុំការបើកសវនាការឡើងវិញ ដើម្បីស្តាប់ការថ្លែងប្រាស្រ័យរបស់ដើមបណ្តឹងរដ្ឋប្បវេណី។[១]

## I. ប្រវត្តិដំណើររឿង

៤. អង្គបុរេជំនុំជម្រះធ្វើការរៀបរាប់ពិស្តារអំពីប្រវត្តិដំណើររឿងនៅក្នុងសេចក្តីសម្រេចមួយនេះ ដើម្បីបង្ហាញអំពីការវិវត្តន៍នៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គបុរេជំនុំជម្រះនៅ អ.វ.ត.ក។

៥. នៅក្នុង "សេចក្តីសម្រេចរបស់ខ្លួនស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន" ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨[២] អង្គបុរេជំនុំជម្រះសម្រេចថា

[១] សេចក្តីបង្គាប់ដល់ភាគីស្តីពីពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ C22/I /56 វាក្យខណ្ឌទី ៥។

[២] សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/53 ("សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ទាំងការចូលរួមដោយសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ត្រូវបានអនុញ្ញាត ហើយអង្គបុរេជំនុំជម្រះបញ្ជាក់ថា នីតិវិធីនៅ អ.វ.ត.ក អនុញ្ញាតការចូលរួមបែបនេះជាកំហិត។[៣] បន្ថែមពីនេះ អង្គបុរេជំនុំជម្រះបានបញ្ជាក់យ៉ាងច្បាស់ថា ការរក្សាតុល្យភាពរវាងសិទ្ធិនីតិវិធីរបស់ភាគី គឺជាដំណើរការមួយដែលមានសារៈសំខាន់ ហើយកំពុងអនុវត្ត។ ដូចគ្នានេះដែរ នីតិវិធីដាច់ខាតហួសហេតុ មិនមែនជាការល្អឡើយ។[៤]

៦. នៅក្នុង "សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លោក នួន ជា" ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ ផងដែរនោះ[៥] អង្គបុរេជំនុំជម្រះបានយោងលើសេចក្តីសម្រេចរបស់ខ្លួនដោយឡែកស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា សារណាដែលដើមបណ្តឹងរដ្ឋប្បវេណី **សេង ច័ន្ទធារី** បានដាក់ជូន "ភាគច្រើនជាទ្រង់ទ្រាយចម្លើយជនរងគ្រោះ" ហើយផ្នែកនៃសារណារបស់គាត់ មិនត្រូវបានយកមកធ្វើការពិចារណានៅក្នុងការសម្រេចលើបណ្តឹងឧទ្ធរណ៍នេះឡើយ។[៦]

៧. មុនថ្ងៃសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន លោក ខៀវ សំផន ដែលបានកំណត់ធ្វើឡើងនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ លោក **នី ចាន់ឌី** ដែលជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី **សេង ច័ន្ទធារី** ទទួលបានការជូនដំណឹងតាមរយៈសារអេឡិចត្រូនិច (អ៊ីម៉ែល) ថា អង្គបុរេជំនុំជម្រះយល់ឃើញថា មានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ ដែលអាចធ្វើសេចក្តីសន្និដ្ឋានបាន។ អង្គបុរេជំនុំជម្រះមិនរំពឹងថា កូនក្តីរបស់លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី នឹងទទួលបានការអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងនោះឡើយ។ លោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់អំពីការទទួលបានសេចក្តីជូនដំណឹងរបស់អង្គបុរេជំនុំជម្រះ មុនថ្ងៃសវនាការ។

៨. ក្នុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន លោក ខៀវ សំផន ដើមបណ្តឹងរដ្ឋប្បវេណី **សេង ច័ន្ទធារី** បានចាប់ផ្តើមធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងជូនអង្គជំនុំជម្រះ ប៉ុន្តែក្រុមប្រឹក្សា

---

[៣] សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី វាក្យខណ្ឌទី ៤២។

[៤] សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី វាក្យខណ្ឌទី ៤៣។

[៥] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនលោក នួន ជា បណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/54 ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន")។

[៦] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ដែលប្តឹងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន វាក្យខណ្ឌទី ៦។

ជំនុំជម្រះបានធ្វើការបញ្ឈប់ ហើយសួរទៅភាគីផងទៃថាតើមានការជំទាស់លើករណីនេះដែរឬទេ។[៧] ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់ថា ខ្លួនចង់ធ្វើការកត់សម្គាល់។ សហមេធាវីរបស់ជនត្រូវចោទ និងសហព្រះរាជ-អាជ្ញាមិនមានការជំទាស់លើបញ្ហានេះឡើយ។ អង្គបុរេជំនុំជម្រះក៏បានអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការកត់សម្គាល់នៅពេលនោះ។

៩. មុនពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន លោកស្រី អៀង ធីរិទ្ធ ដែលបានកំណត់ធ្វើឡើងនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានលើកឡើងការយល់ឃើញរបស់ខ្លួនថា មានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះដែលទទួលបានការអនុញ្ញាតធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់។ នៅក្នុង "សេចក្តីបង្គាប់របស់ខ្លួនស្តីពីការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងពេលសវនាការ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចការឃុំខ្លួនបណ្តោះអាសន្ន" ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨[៨] ("សេចក្តីបង្គាប់ស្តីពីការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី) អង្គបុរេជំនុំជម្រះយល់ឃើញថា "ដើម្បីផលប្រយោជន៍ចំពោះការធានាដល់កិច្ចដំណើរការនីតិវិធីឱ្យដំណើរការបានលឿនទៅមុខ និងដើម្បីផលប្រយោជន៍នៃសេចក្តីដ្ឋានដែលជាប់ពាក់ព័ន្ធ និងដើម្បីជៀសវាងការរាំងស្ទះដល់សវនាការ"[៩] វាជាការសមស្របដែលត្រូវចេញសេចក្តីបង្គាប់បន្ថែម ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍។ អង្គបុរេជំនុំជម្រះបានដកស្រង់វិធាន ២៣(៧) វិធាន ៧៧(៤) និង វិធាន ៧៧(១០)នៃវិធានផ្ទៃក្នុង ដែលចែងអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈមេធាវីតំណាងរបស់ខ្លួន។ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា អនុលោមតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ មេធាវីការពារក្តីគួរដឹងអំពីខ្លឹមសារនៃសេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី មុនពេលសវនាការ។ ម៉្យាងវិញទៀត អង្គបុរេជំនុំជម្រះបានយកលក្ខណៈបច្ចេកទេសនៃសារណាជាលាយលក្ខណ៍អក្សររបស់ភាគីទាំងអស់មកធ្វើការពិចារណា។ ដូច្នេះ អង្គបុរេជំនុំជម្រះពិចារណាឃើញថា តាមការបកស្រាយ វិធានផ្ទៃក្នុងចែងថា ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើសអោយមានមេធាវីតំណាង ត្រូវធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបរបស់ខ្លួន ស្តីពីបណ្តឹងឧទ្ធរណ៍ តាមរយៈមេធាវីតំណាងរបស់ខ្លួន។

[៧] កត់សម្គាល់ឃើញថា សវនាការនេះត្រូវបានរៀបចំឡើង *ជាអសាធារណៈ*។

[៨] សេចក្តីបង្គាប់ចំពោះការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលសវនាការលើបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៨ C20/I/21 ("សេចក្តីបង្គាប់ចំពោះការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី")។

[៩] សេចក្តីបង្គាប់ចំពោះការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី វាក្យខណ្ឌទី ១។

១០. ដើមបណ្តឹងរដ្ឋប្បវេណី **សេខ ចំនួនរ៉ា** មិនមានវត្តមាននៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍លើការឃុំខ្លួនបណ្តោះអាសន្ន អៀង ធីរិទ្ធ ហើយមិនមានមេធាវីតំណាងឱ្យខ្លួនទៀត។

១១. មុនថ្ងៃសវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ដែលកំណត់ធ្វើឡើងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានទទួល "សេចក្តីសង្កេតជាទូទៅពីសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ ("សេចក្តីសង្កេត")។[១០] នៅក្នុងសេចក្តីសង្កេតទាំងនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា សេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះស្តីពីការធ្វើសេចក្តីសន្និដ្ឋាន ដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាការរើសអើងលើដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសិទ្ធិនីតិវិធីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ នៅក្នុង "សេចក្តីសម្រេចលើភាពដែលអាចទទួលបានចំពោះសេចក្តីសង្កេតជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី" ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨[១១] អង្គបុរេជំនុំជម្រះបានលើកឡើងថា ខ្លួនអាចចេញសេចក្តីបង្គាប់ចំពោះបញ្ហានីតិវិធីនេះ ដោយសារយល់ឃើញថាសមស្របក្នុងការគ្រប់គ្រងលើកិច្ចដំណើរការនីតិវិធី។ អង្គបុរេជំនុំជម្រះបានលើកឡើងថា សេចក្តីបង្គាប់ទាំងនេះបិទផ្លូវតវ៉ា ប៉ុន្តែវាអាចបើកផ្លូវចំពោះការពិចារណាសារជាថ្មី ប្រសិនបើមានលេចចេញកាលៈទេសៈថ្មី ឬជាក់លាក់ណាមួយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសង្កេតទាំងនេះ មិនបានលើកអំណះអំណាងជាក់លាក់ឡើយចំពោះការពិចារណាសារជាថ្មីលើសេចក្តីបង្គាប់ស្តីពីការធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សេចក្តីសង្កេតទាំងនេះមិនអាចទទួលយកបាន។

១២. នៅពេលចាប់ផ្តើមសវនាការចំពោះបណ្តឹងឧទ្ធរណ៍ឃុំខ្លួន បណ្តោះអាសន្ន លោក អៀង សារី នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ជាថ្មីម្តងទៀត បានលើកឡើងបញ្ហាបឋមស្តីពីការអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។ នៅក្នុង "សេចក្តីសម្រេចលើបញ្ហាបឋមដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើង នៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន លោក អៀង សារី" នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨[១២] អង្គបុរេជំនុំជម្រះបានលើកឡើងថាៈ "អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់កាលពីលើកមុនថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯងឡើយ ហើយអង្គបុរេជំនុំជម្រះបានផ្តល់សម្អាងហេតុលើបញ្ហានេះ ដោយអនុលោម

---

[១០] សេចក្តីសង្កេតជាទូទៅរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៨ C22/I/38។

[១១] សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃសេចក្តីសង្កេតជាទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ C22/I/41។

[១២] សេចក្តីសម្រេចលើបញ្ហាបន្ទាន់បន្ទំដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ C22/I/46 ("សេចក្តីសម្រេចលើបញ្ហាបន្ទាន់បន្ទំ")។

00221490



តាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង។ យើងមិនឃើញមានការលើកឡើងអំណះអំណាងថ្មី ដែលនឹងនាំឱ្យធ្វើការវិនិច្ឆ័យផ្សេងទៀតអំពីលក្ខណៈទូទៅនេះឡើយ។”[១៣]

១៣. បើទោះជាមានការចេញសេចក្តីសម្រេចនេះក៏ដោយ នៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ សហមេធាវីអន្តរជាតិដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានចង្អុលបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណី **សោខ ច័ន្ទឆារី** នឹងធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង លើចំនុចស្តីពី*គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ*។ អង្គបុរេជំនុំជម្រះបានទទួលការជូនដំណឹងថា ដើមបណ្តឹងរដ្ឋប្បវេណី **សោខ ច័ន្ទឆារី** បានបណ្តេញមេធាវីតំណាងរបស់ខ្លួន។ នៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់ ដែលក្រោយមកបានធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយបានផ្សព្វផ្សាយ “សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯងនោះ” ដែលសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនេះចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨[១៤] (“សេចក្តីសម្រេចលើសំណើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង”) ក្រុមប្រឹក្សាជំនុំជម្រះនៃអង្គបុរេជំនុំជម្រះភាគច្រើនបានសម្រេចថា ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានអនុញ្ញាតឱ្យថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯងឡើយ ដោយលើកឡើងថា: “វិធានផ្ទៃក្នុងមានបទប្បញ្ញត្តិចែងយ៉ាងច្បាស់ស្តីពីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ខ្លួន នៅក្នុងដំណាក់កាលមុនអង្គសេចក្តី។ វិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងចែងថា មានតែមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើសេចក្តីសន្និដ្ឋានសង្ខេបដោយផ្ទាល់មាត់ នៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍មុនអង្គសេចក្តី។”[១៥] ចៅក្រម **Rowan Downing** បានភ្ជាប់មតិជំទាស់របស់គាត់ ដោយលើកឡើងថា យើងឃើញថាវិធាន ២៣ និងវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងហាក់ដូចជាមានភាពផ្ទុយគ្នា។ នៅក្នុងករណីនេះ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីបានបណ្តេញមេធាវីរបស់ខ្លួន ចៅក្រម **Downing** មានបំណងអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការថ្លែងប្រាស្រ័យជូនតុលាការអំពីបញ្ហាយុត្តាធិការ ដោយសារផលវិបាកមួយដែលអាចកើតចេញពីសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍គឺ អាចធ្វើឱ្យសិទ្ធិដាក់បណ្តឹងទាមទារសំណងពីជនត្រូវចោទរលត់។[១៦]

---

[១៣] សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ខំ វាក្យខណ្ឌទី ៨។

[១៤] សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចដោយផ្ទាល់មាត់ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ C22/I/54 (“សេចក្តីសម្រេចលើសំណើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង”)។

[១៥] សេចក្តីសម្រេចលើសំណើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង វាក្យខណ្ឌទី ៣។

[១៦] សេចក្តីសម្រេចលើសំណើសុំការថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង វាក្យខណ្ឌទី ៣។

## II. ពាក្យសុំពិចារណាសារជាថ្មី

១៤. នៅក្នុងពាក្យសុំពិចារណាសារជាថ្មី ដើមបណ្ដឹងរដ្ឋប្បវេណី **សេខ ច័ន្ទធារី** ធ្វើការស្នើសុំឱ្យមានការពិចារណាសារជាថ្មីចំពោះសេចក្ដីសម្រេចលើពាក្យសុំថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង ដោយសម្អាងថា អង្គជំនុំជម្រះមានភស្ដុតាងអង្គហេតុមិនពេញលេញ នៅពេលចេញសេចក្ដីសម្រេចនេះ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបញ្ជាក់ថា នៅក្នុងលិខិតរបស់ខ្លួន និង លិខិតប្រគល់អំណាច ដែលស្នើសុំសហចៅក្រមស៊ើបអង្កេតឱ្យទទួលស្គាល់លោក **នី ចាន់ឌី** ជាមេធាវីរបស់ខ្លួន ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់ថា ខ្លួនចង់ឱ្យមេធាវីតំណាងខ្លួន ហើយ/ឬក៏បានបញ្ជាក់ថា មេធាវីអាចតំណាងខ្លួនគ្រប់ដំណាក់កាលនីតិវិធីទាំងអស់។ ដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា ខ្លួនបានបណ្ដេញមេធាវីរបស់ខ្លួន ដោយសារការតំណាងដោយអាណត្តិនេះមិនមានប្រសិទ្ធិភាព។

១៥. ដើមបណ្ដឹងរដ្ឋប្បវេណី **សេខ ច័ន្ទធារី** បានចង្អុលយោងលើអង្គហេតុបន្ថែមទៀតថា ខ្លួនបានទទួលការអនុញ្ញាតឱ្យថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង នៅក្នុងសវនាការលើរឿងក្ដី នួន ជា និង ខៀវ សំផន ហើយបានផ្ដល់ជូនសេចក្ដីសន្និដ្ឋានដែលពាក់ព័ន្ធជូនតុលាការ។ ម្យ៉ាងវិញទៀត ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្អែកលើការយល់ឃើញរបស់ចៅក្រម Downing ដែលបានលើកឡើងនៅក្នុងមតិជំទាស់។

## III. សេចក្ដីបង្គាប់នានារបស់អង្គបុរេជំនុំជម្រះ

១៦. នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឱ្យភាគីដទៃទៀតធ្វើការឆ្លើយតបទៅនឹងពាក្យសុំពិចារណាសារជាថ្មី។[១៧]

១៧. នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ បន្ទាប់ពីទទួលបានលិខិតមួយច្បាប់ ដែលធ្វើឡើងក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីចំនួនបីរូបដែលគ្មានមេធាវីតំណាង នៅក្នុងសំណុំរឿងរបស់សហចៅក្រមស៊ើបអង្កេតលេខ ០០១ និង ដោយសារទទួលស្គាល់ថា ផលវិបាកអាចកើតមានលើដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង

[១៧] សេចក្ដីបង្គាប់ដល់ភាគីស្ដីពីពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៨ C22/I/56 និង សេចក្ដីកែតម្រូវចំពោះសេចក្ដីបង្គាប់ដល់ភាគីស្ដីពីពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៨ C22/I/5៨។

នៅពេលចេញសេចក្ដីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី អង្គបុរេជំនុំជម្រះបានបើកលទ្ធភាពឱ្យដើមបណ្ដឹងរដ្ឋប្បវេណីទាំងបីរូបនេះ (ដើមបណ្ដឹងរដ្ឋប្បវេណីសំខាន់) និងជនត្រូវចោទផ្សេងទៀត ដាក់សារណា។[១៨]

១៨. សហព្រះរាជអាជ្ញា[១៩] បានទទួលសេចក្ដីសន្និដ្ឋានតប។ ដើមបណ្ដឹងរដ្ឋប្បវេណី[២០] ដែលពាក់ព័ន្ធនៅក្នុងបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួន លោកអៀង សារី បណ្ដោះអាសន្ន បានទទួលសេចក្ដីសន្និដ្ឋានតបរួមគ្នា ហើយដើមបណ្ដឹងរដ្ឋប្បវេណីបីរូបដែលមិនមានមេធាវីតំណាង[២១]នៅក្នុងសំណុំរឿងលេខ ០០១ ក៏បានទទួលសេចក្ដីសន្និដ្ឋាននេះរួមគ្នាដែរ។ តាងនាមជនត្រូវចោទ អៀង សារី ឬជនត្រូវចោទផ្សេងៗទៀត គ្មានឃើញសេចក្ដីសន្និដ្ឋានដទៃទៀតដែលត្រូវទទួលបានឡើយ។

១៩. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ដើមបណ្ដឹងរដ្ឋប្បវេណី **សេង ចំនួនធារី** បានដាក់ "ពាក្យសុំឱ្យធ្វើការប្រកាសជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យដោយខ្លួនឯង មិនមែនជាពាក្យសុំការបើកសវនាការដេញដោលឡើងវិញ"។[២២] អង្គបុរេជំនុំជម្រះយល់ឃើញថា ពាក្យសុំនេះមិនអាចទទួលយកបាន[២៣] ដោយសារពាក្យសុំនេះលើកឡើងអំណះអំណាងពិស្ដារដែលគាំទ្រដល់ពាក្យសុំពិចារណាសារជាថ្មី និងដោយសារ "ការអនុញ្ញាតឱ្យភាគីដទៃឆ្លើយតប មិនអាចយល់ឃើញថាជាការអញ្ជើញភាគីដាក់ពាក្យសុំនេះ ដាក់ពាក្យសុំថ្មីមួយទៀតឡើយ ចំពោះបញ្ហាដែលអង្គជំនុំជម្រះកំពុងពិចារណា ឬដាក់អំណះអំណាងបន្ថែមដើម្បីគាំទ្រដល់ពាក្យសុំដំបូងនោះទេ។"[២៤]

---

[១៨] សេចក្ដីបង្គាប់បន្ថែមដល់ភាគីស្ដីពីពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ C22/I/59។

[១៩] សេចក្ដីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញាចំពោះពាក្យសុំពិចារណាសារជាថ្មីលើសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះស្ដីពីសិទ្ធិចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ C22/I/61។

[២០] សេចក្ដីសង្កេតរួមរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីលើពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ C22/I/60។

[២១] សារណាតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង ចំពោះពាក្យសុំពិចារណាសារជាថ្មីលើសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២០ ខែកក្កដា ២០០៨ C22/I/63។

[២២] ពាក្យសុំឱ្យធ្វើការប្រកាសជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការថ្លែងប្រាស្រ័យដោយខ្លួនឯង មិនមែនចំពោះការសុំឱ្យបើកសវនាការសារជាថ្មី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ C22/I/62។

[២៣] សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំឱ្យធ្វើការប្រកាសជាប្រយោជន៍ដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំពោះការថ្លែងប្រាស្រ័យដោយខ្លួនឯង មិនមែនចំពោះការសុំឱ្យបើកសវនាការសារជាថ្មី ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ C22/I/64។ ("សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំឱ្យធ្វើការប្រកាសជាប្រយោជន៍")។

[២៤] សេចក្ដីសម្រេចស្ដីពីភាពអាចទទួលយកបាននៃពាក្យសុំឱ្យធ្វើការប្រកាសជាប្រយោជន៍ វាក្យខណ្ឌទី ៤។



PRE-TRIAL CHAMBER * E.C.C.C * C.E.T.C * CHAMBRE PRÉLIMINAIRE

## IV. សេចក្ដីសន្និដ្ឋានតបរបស់ភាគី

២០. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនៅបណ្ដឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនជនត្រូវចោទ បណ្ដោះអាសន្នសន្និដ្ឋានថា ពាក្យសុំពិចារណាសារជាថ្មីគួរយល់ថា ជាពាក្យសុំសេចក្ដីសម្រេចជាប្រយោជន៍ចំពោះ សិទ្ធិចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខអង្គបុរេជំនុំជម្រះ ដែលវាមិនមែនជាពាក្យសុំឱ្យបើក សវនាការជំនុំជម្រះឡើងវិញនោះទេ។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតវ៉ាថា អង្គបុរេជំនុំជម្រះបានអនុវត្ត វិធីសាស្ត្របកស្រាយមួយដែលតឹងរ៉ឹងបំផុតចំពោះវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង ដែលវិធីសាស្ត្រនេះផ្ទុយនឹង វិធីសាស្ត្រដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ហើយវិធានផ្ទៃក្នុងនេះមិនបានកត់សម្គាល់ឃើញមានចន្លោះប្រហោង នៅពេលព្រាងវិធាន ៧៧(១០)នៃវិធានផ្ទៃក្នុងនេះ។ ការប្រៀបធៀបត្រូវបានទាញចេញនៅពេលពិនិត្យមើលលទ្ធភាព របស់ជនត្រូវចោទក្នុងការផ្ដល់ចម្លើយ។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា វិធាន២៣(៧) នៃវិធានផ្ទៃក្នុងចែងអំពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការទទួលបានតំណាងមេធាវី។ វិធាននេះមិនមែនចែង អំពីកាតព្វកិច្ចត្រូវមានមេធាវីតំណាងនោះឡើយ។ យើងអាចតវ៉ាថា កាតព្វកិច្ចនេះនឹងមិនមានភាពយុត្តិធម៌ នៅពេលមិនមានថវិកាសម្រាប់មេធាវីតំណាងដែល អ.វ.ត.ក ជាអ្នកផ្ដល់ជូន។ សហមេធាវីដើមបណ្ដឹងរដ្ឋប្ប-វេណីលើកឡើងថា ការជ្រើសរើសយកមេធាវីធ្វើជាតំណាង មិនមែនបង្កប់ន័យថាជាការបោះបង់សិទ្ធិនិយាយ ដោយខ្លួនឯងនោះទេ ដោយសារអ្នកធ្វើសេចក្ដីព្រាងវិធានផ្ទៃក្នុង យល់ឃើញថា ការមានមេធាវីតំណាងគឺជាការធ្វើ ឱ្យឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណីកាន់តែប្រសើរឡើង។ សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជម្រុញអង្គបុរេជំនុំ ជម្រះឱ្យអនុវត្តការបកស្រាយវិធានផ្ទៃក្នុងក្នុងន័យមួយដែលមានលក្ខណៈប្រព័ន្ធ និងតាមគោលការណ៍ Teleological ដោយធ្វើការយោងលើវិធាន២១(១) នៃវិធានផ្ទៃក្នុងផងដែរ។ នៅក្នុងចំនុចចុងក្រោយ សហមេធាវី ដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ឃើញថា បទបញ្ញត្តិកំណត់រយៈពេលដែលបានកំណត់ឡើងក្នុងពេលសវនាការ មានន័យថា ការអនុញ្ញាតឱ្យដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងប្រាស្រ័យក្នុងតុលាការ នឹងមិននាំឱ្យមានការពន្យារពេល ដំណើរការនីតិវិធីឡើយ។

២១. យោងតាមយុត្តិសាស្ត្រអន្តរជាតិស្ដីពីករណីពិចារណាសារជាថ្មី ឬសើរើឡើងវិញ ជាពិសេសនៅក្នុង រឿងក្ដី *Barayagwiza*[២៥] សហព្រះរាជអាជ្ញាតវ៉ាថា ការសាកល្បងចំពោះការពិចារណាសារជាថ្មីមិនមែនជា ប្រយោជន៍ដែលគួរឱ្យជឿជាក់នោះទ ដូច្នេះពាក្យសុំនេះគួរតែបដិសេធចោល។ សហព្រះរាជអាជ្ញាធ្វើការលើក អំណះអំណាងបន្ថែមដែលពាក់ព័ន្ធនឹងសិទ្ធិតំណាងដោយខ្លួនឯង និង លក្ខខណ្ឌកម្រិតចំពោះសិទ្ធិនេះ ដោយបំផុត

---

[២៥] *រដ្ឋអាជ្ញា ទល់នឹង Barayagwiza* ICTR-97-19-AR72 "សេចក្ដីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឱ្យសើរើ ឬពិចារណាសារជាថ្មី" ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០០។

ថា តុលាការមានអំណាចអនុញ្ញាតឱ្យចុងចោទចូលរួមដោយខ្លួនឯង ឬមានអំណាចបង្គាប់ឱ្យមេធាវីតំណាងរឿងក្តីនេះទាំងស្រុងតែម្តង ដោយអាស្រ័យតាមកាលៈទេសៈ។ តាមការលើកឡើងរបស់សហព្រះរាជអាជ្ញា យុត្តិសាស្ត្រចំពោះករណីចុងចោទតំណាងខ្លួនឯង អាចជាប្រយោជន៍ក្នុងការសម្រេចអំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ សហព្រះរាជអាជ្ញាសង្កត់ធ្ងន់ថា អង្គជំនុំជម្រះគួរបញ្ញត្តិការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយរួមទាំងសិទ្ធិក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះដោយផ្ទាល់ ដើម្បីផ្តល់តុល្យភាពល្អត្រឹមត្រូវរវាងសិទ្ធិចូលរួមឱ្យបានពេញលេញនៅក្នុងដំណើរកាលនីតិវិធី របស់ជនរងគ្រោះដែលអាចមានចំនួនកើនឡើង និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឆាប់រហ័សរបស់ចុងចោទ។ សហព្រះរាជអាជ្ញាលើកឡើងថា យើងគួរស្វែងរកដំណោះស្រាយចំពោះភាពផ្ទុយគ្នានៃបទប្បបញ្ញត្តិវិធាន ២៣(៧) និង វិធាន ៧៧(១០)នៃវិធានផ្ទៃក្នុង ដើម្បីផ្តល់ប្រយោជន៍ដល់ដើម្បីបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងចំនុចចុងក្រោយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អង្គហេតុនៅក្នុងពាក្យសុំពិចារណាសារជាថ្មី មិនបានស្នើសុំឱ្យបើកសវនាការដេញដោលសារជាថ្មីនោះទេ ប៉ុន្តែស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើការដាក់ចេញសេចក្តីណែនាំសម្រាប់សវនាកាលនាពេលក្រោយៗទៀត ដោយក្នុងនោះ គួរបញ្ញត្តិសិទ្ធិថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះដោយខ្លួនឯង របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង។

២៣. ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង សន្និដ្ឋានថា ពាក្យសុំពិចារណាសារជាថ្មីគួរអាចទទួលយកបាន ហើយគួរបើកសវនាការដេញដោលឡើងវិញ ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណី **សេខ ចំនួធារី** ធ្វើការសន្និដ្ឋាន។ ដើមបណ្តឹងរដ្ឋប្បវេណីតវ៉ាថា វិធាន ២៣(១)(ក) នៃវិធានផ្ទៃក្នុង ដូចដែលមានចែងបញ្ជាក់នៅក្នុងវិធាន ២៣(៨) នៃវិធានផ្ទៃក្នុង មិនតម្រូវឱ្យមានការចូលរួមតាមរយៈមេធាវីតំណាង ហើយវិធានផ្ទៃក្នុងអនុញ្ញាតដោយប្រយោលឱ្យដើមបណ្តឹងរដ្ឋប្បវេណីជ្រើសរើសមេធាវីតំណាងខ្លួន។ ដោយកត់សម្គាល់ថា វិធាន ៧៧(១០) នៃវិធានផ្ទៃក្នុង ចែងអំពីសេចក្តីសង្កេតសង្ខេបរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាងលើកឡើងថា ក្នុងនាមភាគីនៅក្នុងរឿងក្តី ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងត្រូវមានលទ្ធភាពអនុវត្តមុខងារទាំងអស់ ដែលផ្តល់ដល់ភាគីផ្សេងៗទៀត ទោះបីជាមិនមានមេធាវីតំណាងក៏ដោយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងកត់សម្គាល់ថា ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្លុះបញ្ចាំងវិធានផ្ទៃក្នុងក្នុងន័យថា មេធាវីអាចធ្វើសេចក្តីសង្កេតផ្ទាល់មាត់ដោយសង្ខេបនៅដំណាក់កាលមុនអង្គសេចក្តី ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងយ៉ាងច្បាស់ ដោយអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីសន្និដ្ឋាន (ទោះបីមាន ឬគ្មានមេធាវីតំណាងក៏ដោយ) នៅក្នុងដំណាក់ការជំនុំជម្រះ។ យើងកត់សម្គាល់ឃើញថា ទាំងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មិនមានចែងអំពីករណីដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាង នៅក្នុងដំណាក់កាលមុនអង្គសេចក្តី។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង

E.C.C.C. * C.E.T.C. PRE-TRIAL CHAMBER CHAMBRE

00221495



គួរហាមមិនឱ្យធ្វើសេចក្តីសន្និដ្ឋានដោយផ្ទាល់មាត់ដោយខ្លួនឯងនៅក្នុងដំណាក់កាលមុនអង្គសេចក្តី យោងតាមគោលបំណងរបស់អ្នកធ្វើសេចក្តីព្រាងវិធានផ្ទៃក្នុង ហើយការរារាំងដូច្នេះមិនមែនជាការបំពារបំពានសិទ្ធិក្នុងការបង្ហាញការយល់ឃើញ និងការចាប់អារម្មណ៍របស់ពួកគេឡើយ ឬក៏ជម្រុញឱ្យពួកគេបណ្តេញមេធាវីដើម្បីថ្លែងប្រាស្រ័យដោយខ្លួនឯងនោះឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ ដើមបណ្តឹងរដ្ឋប្បវេណីដែលគ្មានមេធាវីតំណាងតវ៉ាថា ការយល់វិធានផ្ទៃក្នុងក្នុងន័យមួយត្រឹមត្រូវ គឺវិធានផ្ទៃក្នុងនេះផ្តល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង (ដែលអាចគ្មានមេធាវីតំណាង ដោយសារមិនមានថវិកា តែមិនមែនដោយសារបញ្ហានៃការជ្រើសរើសមេធាវីតំណាង) នូវសិទ្ធិទាំងឡាយ ដូចគ្នាទៅនឹងសិទ្ធិដែលដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតទទួលបាន។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ជំរុញអង្គបុរេជំនុំជម្រះឱ្យប៉ះប៉ូវធានាដល់ខ្លួននូវសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលកំពុងតែកើនឡើង ដោយរៀបចំកិច្ចដំណើរការនីតិវិធីឱ្យបានរឹងមាំ ដើម្បីធានាដំណើរការនីតិវិធីទៅឆាប់រហ័ស។

២៣. ដោយសារសហមេធាវីការពារក្តីរបស់ជនត្រូវចោទមិនបានដាក់សេចក្តីសន្និដ្ឋានតប សហមេធាវីការពារក្តីអន្តរជាតិបានលើកឡើងនៅក្នុងពេលសវនាការថា សវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន មិនមែនដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មនោះទេ។ សហមេធាវីការពារក្តីបានអះអាងថា នៅក្នុងដំណាក់កាលក្រោយ ទោះបីមេធាវីការពារក្តីគាំទ្រពេញលេញលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើសេចក្តីសន្និដ្ឋាន និងមានមេធាវីតំណាងក៏ដោយ ប្រព័ន្ធនៃវិធានផ្ទៃក្នុងបានតាក់តែងឡើងដើម្បីអនុញ្ញាតដើមបណ្តឹងរដ្ឋប្បវេណីប្រមូលផ្តុំធនធានរបស់ខ្លួន តាមរយៈមេធាវីតំណាងរបស់ខ្លួន។

២៤. អង្គបុរេជំនុំជម្រះបញ្ជាក់ថា ការព្រួយបារម្ភដែលដើមបណ្តឹងរដ្ឋប្បវេណីមិនមានមេធាវីតំណាងលើកឡើង នឹងធ្វើការបកស្រាយនៅក្នុងសេចក្តីសម្រេចដោយឡែក។

## IV. **ពាក្យសុំពិចារណាសារជាថ្មី**

២៥. ពាក្យសុំពិចារណាសារជាថ្មីអាចទទួលយកបាន ប្រសិនបើមានមូលដ្ឋានស្របច្បាប់ដាក់ជូនអង្គបុរេជំនុំជម្រះ ដើម្បីឱ្យធ្វើការពិចារណាសេចក្តីសម្រេចរបស់ខ្លួនកាលពីលើកមុន។[២៦] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវីបានសម្រេចថា អង្គជំនុំជម្រះ ផ្សេងពីនេះ...

---

[២៦] *រដ្ឋអាជ្ញា ទល់នឹង Milosevic* IT-02-54-T "សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឱ្យពិចារណាសារជាថ្មីលើភស្តុតាងរបស់សាក្សីដោះបន្ទុក Mitar Balevic, Vladislav Jovanovic, Vukasin Andric, និង Dobre Aleksovski" ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ វាក្យខណ្ឌទី ៦។

“ពិចារណាសេចក្តីសម្រេច ដែលខ្លួនបានចេញកាលពីលើកមុនសារជាថ្មី តែការពិចារណាសារជាថ្មីនេះ មិនមែនដោយសារមានកាលៈទេសៈប្រែប្រួលប៉ុណ្ណោះនោះទេ គឺអាចដោយសារនៅពេលដែលខ្លួនយល់ឃើញថា សេចក្តីសម្រេចលើកមុនមានកំហុស ឬបណ្តាលឱ្យមានភាពអយុត្តិធម៌។”[២៧] អំណាចនេះអាចពិពណ៌នាថា ជាអំណាចឆន្ទានុសិទ្ធិ[២៨] ហើយជាពិសេស អំណាចនេះជាជម្រើសចុងក្រោយដែលមានភាពចាំបាច់សម្រាប់ស្ថាប័នតុលាការដូចអង្គបុរេជំនុំជម្រះនេះ។ ការផ្លាស់ប្តូរនូវកាលៈទេសៈអាចរួមបញ្ចូលអង្គហេតុថ្មី ឬអំណះអំណាងថ្មី។[២៩] បទដ្ឋានចំពោះការពិចារណាសារជាថ្មី ត្រូវបានពិពណ៌នាដូចតទៅ: “អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិដោយឯកឯង ក្នុងការពិចារណាសេចក្តីសម្រេចបន្ទាន់បន្ទំដែលបានចេញការពីលើកមុន សារជាថ្មី នៅក្នុងករណីពិសេស “ប្រសិនបើមានកំហុសចំពោះអំណះអំណាងច្បាស់លាស់ ឬ ប្រសិនបើចាំបាច់ក្នុងការរារាំងភាពអយុត្តិធម៌។””[៣០]

២៦. អង្គបុរេជំនុំជម្រះមិនឃើញមានការលើកឡើងអង្គហេតុថ្មី អំណះអំណាងថ្មី ឬការប្រែប្រួលកាលៈទេសៈ នៅក្នុងពាក្យសុំពិចារណាសារជាថ្មី។ លិខិតផ្តល់អំណាចចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ និងសេចក្តីសម្រេចទទួលស្គាល់មេធាវី ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ដែលដាក់ភ្ជាប់នឹងពាក្យសុំ មិនមានអ្វីថ្មីឡើយ ហើយលិខិត និងសេចក្តីសម្រេចទាំងអស់នេះមាននៅក្នុងសំណុំរឿងរួចហើយ មុនពេលអង្គបុរេជំនុំជម្រះចេញសេចក្តីសម្រេចលើសំណើសុំថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង។

២៧. បន្ថែមពីនេះ ដើមបណ្តឹងរដ្ឋប្បវេណី **សេង ចំនូធារី** មិនបានបង្ហាញថា សេចក្តីសម្រេច មានអានុភាពបណ្តាលឱ្យមានលទ្ធផលដែលមិនអាចស្មានដល់ ដែលនាំដល់មានភាពអយុត្តិធម៌ឡើយ។

២៨. អត្ថិភាពនៃមតិជំទាស់ មិនមែនបញ្ជាក់ពីភាពត្រឹមត្រូវចំពោះការពិចារណាសារជាថ្មីឡើយ។ ករណីដែលដើមបណ្តឹងរដ្ឋប្បវេណី មិនពេញចិត្តចំពោះសម្អាងហេតុ មានសសេរនៅក្នុងមតិជំទាស់។

---

[២៧] *រដ្ឋអាជ្ញា ទល់នឹង Galic* IT-98-29-AR73 “សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញាសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍” ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០១ វាក្យខណ្ឌទី ១៣។ *រដ្ឋអាជ្ញា ទល់នឹង Mucic et al.*, IT-96-21-*Abis* “សាលដីកាលើបណ្តឹងឧទ្ធរណ៍ចំពោះការផ្តន្ទាទោស” ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៣ វាក្យខណ្ឌទី ៤៩។

[២៨] *រដ្ឋអាជ្ញា ទល់នឹង Galic* IT-98-29-A “សេចក្តីសម្រេចលើសំណើរបស់មេធាវីចុងចោទសុំឱ្យពិចារណាសារជាថ្មី” ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ វាក្យខណ្ឌទី ២។

[២៩] *រដ្ឋអាជ្ញា ទល់នឹង Galic* IT-98-29-A “សេចក្តីសម្រេចលើសំណើរបស់មេធាវីចុងចោទសុំឱ្យពិចារណាសារជាថ្មី” ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៤ វាក្យខណ្ឌទី ២។

[៣០] *រដ្ឋអាជ្ញា ទល់នឹង Milosevic et al.*, IT-05-87-T “សេចក្តីសម្រេចលើសំណើរបស់រដ្ឋអាជ្ញា សុំឱ្យពិចារណាសារជាថ្មីលើសេចក្តីសម្រេចស្តីពីសំណើរបស់រដ្ឋអាជ្ញាសុំវិធានការការពារបន្ថែម នៅក្នុងដំណាក់ការជំនុំជម្រះ ដើម្បីការពារសាក្សី K56” ចុះថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០០៦ វាក្យខណ្ឌទី ២។

C22/I/68

**ដូច្នេះ អង្គបុរេជំនុំជម្រះសម្រេច:**

(១) បដិសេធចោលពាក្យសុំពិចារណាសារជាថ្មី លើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដែលដើមបណ្តឹងរដ្ឋប្បវេណី **សេង ចំនួនឆារី** ដាក់ជូន។

(២) មិនបើកសវនាការដេញដោលសារជាថ្មីទេ។

ភ្នំពេញ ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**